វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ: ១០៧ប្រក/ថ្ងៃទី១៩ ខែសីហា ឆ្នាំ ២០០២

## ប្រកាសស្តីពីការរៀបចំលេខាធិការដ្ឋាន នៃគណៈកម្មការសុរិយោដីក្រុងកែប និងសមាសភាពគណៈកម្មការសុរិយោដីខណ្ឌក្នុងក្រុងកែប

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ១៩៩៩ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង
- បានឃើញព្រះរាជក្រម លេខនស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការ សុរិយោដី
- បានឃើញអនុក្រឹត្យលេខ ៣៤៧ អនក្រ.តត.ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០២ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការសុរិយោដីថ្នាក់ជាតិ
- យោងប្រកាសអន្តរក្រសួងលេខ០៧៧ ប្រកចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០២ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង
- តាមសំណើររបស់គណៈកម្មការសុរិយោដីក្រុងកែប

**សំរេច**

ប្រការ ១ :

ត្រូវបានបង្កើតលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីក្រុងកែប ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- លោក ព្រំ ហុង | អនុប្រធានមន្ទីរ ដនសស.ក្រុងកែបទទួលបន្ទុកការងារសុរិយោដី | ជាប្រធាន |
| ២- លោក អ៊ុក រឿន | ប្រធានការិ. នៃមន្ទីរ ដនសស.ក្រុងកែប | ជាអនុប្រធាន |
| ៣- លោក ស្រេង សុផល | អនុប្រធានការិយាល័យសុរិ.និងភូមិសាស្ត្រនៃមន្ទីរដ.ន.ស.ស ក្រុងកែប | ជាមន្ត្រីជំនួយការ |

ប្រការ ២ :

ត្រូវបានរៀបចំសមាសភាពគណៈកម្មការសុរិយោដីខណ្ឌក្នុងក្រុងកែប ដូចខាងក្រោម :

ក. គណៈកម្មការសុរិយោដីខណ្ឌកែប :

| | | |
|---|---|---|
| ១- លោក ឈុំ ម៉ានី | អនុប្រធានទទួលបន្ទុកការងាររួមការិយាល័យ ដនសភ ខណ្ឌកែប | ជាប្រធាន |
| ២- លោក វិញ ផុល | អនុប្រធាន ការិយាល័យ ដនសភ ខណ្ឌកែប | ជាសមាជិក |
| ៣- លោក ឈន សុភ័ក្រ | មន្ត្រីការិយាល័យ ដនសភ ខណ្ឌកែប | ជាសមាជិក |

Downloaded from http://www.khmerlaws.com

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

ខ. គណៈកម្មការសុរិយោដីខណ្ឌដំណាក់ចង្អើរ :

| | | |
|---|---|---|
| ១- លោក សយ ច័ន្ទរ៉ាវុធ | អនុប្រធានទទួលបន្ទុកការងាររួមការិយាល័យ ដនសភខណ្ឌដំណាក់ចង្អើរ | ជាប្រធាន |
| ២-លោក ចាំង ខេងហួត | មន្ត្រីការិយាល័យ ដនសភខណ្ឌដំណាក់ចង្អើរ | ជាសមាជិក |
| ៣- លោក សយ រដ្ឋា | មន្ត្រីការិយាល័យ ដនសភ ខណ្ឌដំណាក់ចង្អើរ | ជាសមាជិក |

ប្រការ ៣ :

លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីក្រុង គណៈកម្មការសុរិយោដីខណ្ឌទាំងអស់ក្នុងក្រុងកែប មានបេសកកម្មអនុវត្តនូវភារកិច្ចរបស់ខ្លួន ដូចមានចែងក្នុងអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ។

ប្រការ ៤:

នាយកខុទ្ទកាល័យ ប្រធានលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ប្រធានគណៈកម្មការសុរិយោដីក្រុងកែប ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីក្រុងកែប អស់លោក ដូចមានរាយនាមក្នុងប្រការ ១ និងប្រការ២ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

Downloaded from http://www.khmerlaws.com